ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស
លេខៈ ០០៥/១៣ សរបក.ពបព

# សេចក្តីប្រកាសព័ត៌មាន

## សារមន្ទីរមេត្រូប៉ូលីតែន (Metropolitan Museum) នៅទីក្រុងញូវយ៉ក សំរេចប្រគល់រូបបដិមាខ្មែរមកឱ្យកម្ពុជាវិញ។

ក្រោយពីការពិភាក្សាជាច្រើនលើកជាមួយទីស្តីការគណរដ្ឋមន្ត្រីមក សារមន្ទីរ Metropolitan នៅទីក្រុងញូវយ៉ក នៅពេលថ្មីៗនេះ បានសំរេចចិត្តប្រគល់មកឱ្យព្រះរាជាណាចក្រកម្ពុជាវិញ នូវរូបបដិមាថ្មពីរនៃសតវត្សរ៍ទី ១០ ដែលមានឈ្មោះថា "បនទវៈ លុតជង្គង់" (Kneeling Pandawas) ពេលខ្លះត្រូវបានគេស្គាល់ថា "ជាអ្នកបំរើ លុតជង្គង់" (Kneeling Attendants) ដែលត្រូវបានគេលួចចេញពីប្រាសាទចិន នៅកោះកែរ អំឡុងពេលនៃសង្គ្រាមស៊ីវិលក្នុងប្រទេសកម្ពុជា នាទសវត្សរ៍ទី៧០។

រូបទាំងពីរនេះ ជាផ្នែកមួយនៃរូបបដិមាមួយក្រុមដែលតំណាងឱ្យការប្រយុទ្ធតស៊ូដ៏ល្បីល្បាញរវាង ភីម (Bhima) និងឌូរីយោដាន (Duryodhana) នៃរឿងព្រេងមហាភារតៈ (Mahabharat) ហើយដែលត្រូវបានគេកាច់បំបាក់យ៉ាងឃោរឃៅចេញពីជើងទម្ររបស់វា និងបញ្ជូនចេញទៅសារមន្ទីរ និងការសន្សំទុកឯកជននានាជុំវិញពិភពលោក។

នៅក្នុងសេចក្តីប្រកាសព័ត៌មានរបស់ខ្លួនចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ២០១៣ សារមន្ទីរ Metropolitan បានដកស្រង់សំដីនាយករបស់ខ្លួនលោក Thomas P. Campbell ថាៈ «សារមន្ទីរប្តេជ្ញាចិត្តអនុវត្តយ៉ាងហ្មត់ចត់នូវបទដ្ឋាននៃទីកន្លែងដើម គឺមិនគ្រាន់តែទៅលើរបស់ដែលទើបទទួលបានថ្មីៗប៉ុណ្ណោះទេ គឺថែមទាំងទៅលើការសិក្សាស្វែងយល់ពីការងារក្នុងការប្រមែប្រមូលសន្សំទុករបស់ខ្លួនដ៏យូរយារមកហើយ ក្នុងកិច្ចខិតខំប្រឹងប្រែងដែលកំពុងតែប្រព្រឹត្តទៅដើម្បីសិក្សាស្វែងយល់ឱ្យបានច្រើនដែលអាចធ្វើបានទៅលើប្រវត្តនៃកម្មសិទ្ធិផងដែរ»។ នេះជាករណីមួយដែលក្នុងនោះព័ត៌មានបន្ថែម... បានធ្វើឱ្យសារមន្ទីរពិចារណាទៅលើភាពពិតជាក់ស្តែងដែលមិនបានដឹងនៅពេលដែលបានទទួលនិងចាត់វិធានការ...។ ក្នុងការបញ្ជូនត្រឡប់មកវិញនូវរូបបដិមាទាំងពីរនេះ លោក Thomas P. Campbell នាយកសារមន្ទីរ Metropolitan បានមានប្រសាសន៍ថាៈ "...សារមន្ទីរកំពុងតែពង្រឹងទំនាក់ទំនង ល្អ ដែលខ្លួនបានរក្សាជាយូរមកហើយនោះ ជាមួយនឹងស្ថាប័នអ្នកសិក្សាស្រាវជ្រាវ និងសហសេវិកកម្ពុជា ក៏ដូចជាការជំរុញ និងបន្តនូវទំនាក់ទំនងល្អព្រមទាំងកិច្ចពិភាក្សាល្អរវាងគ្នា និងគ្នា"។៚

ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៤១ មហាវិថីសហព័ន្ធរុស្ស៊ី
ទូរសារលេខៈ ០២៣ ២១២ ៩៤០, ទូរស័ព្ទៈ ០១២ ៩៩៩ ៩៧៦, ០៩៧ ៧ ៩៧០ ៦០៩
អ៊ីមែលៈ pressocm@gmail.com

ឯកឧត្តម ច័ន្ទ តានី រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវបានគេដកស្រង់សំដីនៅក្នុងសារព័ត៌មាន International herald Tribune ពីថ្ងៃទី ៤-៥ ខែ ឧសភា ឆ្នាំ២០១៣ ថាៈ «កាយវិការខាងលើនេះ បានបង្ហាញឲ្យឃើញនូវកម្រិតក្រមសីលធម៌ និងការអនុវត្តបែបវិជ្ជាជីវៈដ៏ត្រឹមត្រូវរបស់សារមន្ទីរ Metropolitan ដែលកិច្ចការនេះត្រូវបានគេដឹងឮជាទូទៅ។ ករណីនេះ ក៏នឹងជួយពង្រឹងនូវសហប្រតិបត្តិការដ៏ល្អឥតខ្ចោះ រវាងសារមន្ទីរ Metropolitan និងសហភាគីកម្ពុជាក្នុងវិស័យបេតិកភណ្ឌវប្បធម៌»។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការបេតិកភណ្ឌពិភពលោក បានថ្លែងនៅឯទីស្នាក់ការអង្គការ UNESCO នៅប៉ារីស ថ្ងៃនេះថា «យើងសូមយកឱកាសដ៏ឧឡារិកនេះ ដើម្បីសំដែងនូវអំណរគុណដ៏ស្មោះស្ម័គ្រ និងការដឹងគុណដ៏ជ្រាលជ្រៅបំផុត ជូនចំពោះសារមន្ទីរ Metropolitan នៅញ៉ូវយ៉ក ដែលបានចេញសេក្តីសំរេចចិត្តគួរឱ្យស្ញប់ស្ញែងក្នុងការប្រគល់ជូនមកវិញនូវសម្បត្តិវប្បធម៌បុរាណខ្មែរដែលមិនអាចកាត់ថ្លៃបាន និងដែលតំណាងឱ្យផ្នែកមួយនៃព្រលឹងជាតិកម្ពុជា»។ យើងក៏សូមអរគុណរដ្ឋាភិបាលអាមេរិកផងដែរ ដែលបានផ្តល់នូវការគាំទ្ររបស់ខ្លួនចំពោះកិច្ចខិតខំប្រឹងប្រែងនេះ។

លើសពីនេះទៀត រាជរដ្ឋាភិបាលកម្ពុជាសូមអំពាវនាវដល់សារមន្ទីរនានា និងការប្រមូលទុកនៅកន្លែងផ្សេងៗទៀតនូវសម្បត្តិវប្បធម៌ជុំវិញពិភពលោក ធ្វើតាមគំរូក្នុងការផ្តល់ទៅម្ចាស់ពេញសិទ្ធិដើមវិញនូវសម្បត្តិវប្បធម៌ ដែលត្រូវបានគេលួចប្លន់យកទៅ ហើយនេះក៏ជាផ្នែកមួយនៃយុទ្ធនាការពិភពលោកក្នុងការការពារបេតិកភណ្ឌវប្បធម៌។

ការបញ្ជូនត្រឡប់មកវិញនូវរូបបដិមាទាំងនេះ អាចត្រូវបានគេឲ្យតម្លៃទៅលើការខិតខំប្រឹងប្រែងដ៏ខ្លាំងក្លារបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ហើយនេះមិនត្រឹមតែជាជោគជ័យរបស់រាជរដ្ឋាភិបាលកម្ពុជាប៉ុណ្ណោះទេ ក៏ប៉ុន្តែវាក៏ជាជោគជ័យ និងជាមោទនភាពរបស់ប្រជាជាតិកម្ពុជាទាំងមូលផងដែរ ។ឥ/

រាជធានីភ្នំពេញ ថ្ងៃ ៩ ខែ ឧសភា ឆ្នាំ២០១៣
អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស